# បូរ៉ាទីណូ

BORADINO

ឯកសារនេះរៀបរៀង និងផលិតដោយ ភូ ចរិយា ដែលអាចឲ្យ download ដោយមិនគិតថ្លៃនៅលើគេហទំព័រ https://chantchhaya.com/

របៀបរស់នៅ និងរបៀបគិតរបស់កូនក្មេងគឺសាមញ្ញណាស់។ អ្វីក៏សប្បាយ អ្វីក៏អស្ចារ្យ សូម្បីតែម្សិលមិញចុះជណ្ដើរតោងបង្កាន់ដៃ ហើយថ្ងៃនេះអាចចុះដោយមិនបាច់កាន់បង្កាន់ដៃ។

## តើភ្លឺស្រែគឺជាអ្វី ?

ភ្លឺស្រែគឺជាដីដែលកសិករលើកឲ្យខ្ពស់ជុំវិញស្រែ ដើម្បីធ្វើជាទំនប់ទប់ទឹកផង និងសម្រាប់សម្គាល់ថា ស្រែណាជារបស់អ្នកណាផង។

## តើឈ្មោះផ្លូវការរបស់ស៊ីក្លូជាអ្វី ?

ឈ្មោះជាផ្លូវការរបស់ស៊ីក្លូគឺ «ត្រីចក្រយាន»។ ត្រី មានន័យថា បី, ចក្រ មានន័យថា កង់, យាន មានន័យថា គ្រឿងសម្រាប់ជិះ។

## តើមាតុភូមិមានន័យដូចម្ដេច ?

ភូមិ មានន័យថា ប្រទេស។ មាតុ មានន័យថា កំណើត។ មាតុភូមិ មានន័យថា ប្រទេសកំណើត។

## ធ្វើដូចម្ដេចទើបអាចចំណាំទិសបាន ?

នៅពេលព្រឹក ព្រះអាទិត្យនៅខាងណា ខាងនោះហៅថា ទិសខាងកើត។ ទិសដែលនៅទល់មុខនឹងទិសខាងកើត ហៅថា ទិសខាងលិច។ បើសិនជាចង់ដឹងថាទិសមួយណាជាខាងជើង និងខាងត្បូង យើងត្រូវឈរបែរខ្នងដាក់ទិសខាងកើត រួចមើលៈ ដៃស្ដាំនៅខាងណា ខាងនោះជាទិសខាងជើង, រីឯទិសនៅខាងឆ្វេងដៃជាទិសខាងត្បូង។




## សត្វមាន់



មាន់ ជាបក្សី។ មាន់ដែលចិញ្ចឹមដោយមនុស្សហៅថា «មាន់ស្រុក»។ ចំណែកមាន់ដែលរស់នៅក្នុងព្រៃ ហៅថា មាន់ព្រៃ។ មាន់ស្រុក និង មាន់ព្រៃមានរូបរាងប្រហាក់ប្រហែលគ្នា តែមានចំណុចខុសគ្នា ដែលអាចឲ្យសម្គាល់បានថា មួយណាជាមាន់ស្រុក មួយណាជាមាន់ព្រៃ គ្រាន់តែត្រូវការអ្នកដឹង និងស្គាល់ទើបអាចប្រាប់បានថាសម្គាល់យ៉ាងដូចម្ដេច។

អ្នកខ្លះហៅមាន់ស្រុកថា មាន់សម្ល ដោយសារតែជាទូទៅពួកវាត្រូវបានចិញ្ចឹមដើម្បីធ្វើជាចំណីរបស់មនុស្ស។

មាន់មានឈ្មោលមានញី។ មាន់ឈ្មោល ហៅថា មាន់គក, មាន់ញី ហៅថា មេមាន់, ឯកូន ហៅថា កូនមាន់។

មាន់ ត្រូវបានហៅថា សត្វមានកំណើតពីរដង។ កំណើតទីមួយ ជាស៊ុតនៅក្នុងពោះមេរបស់វា។ កំណើតទីពីរ កើតចេញជាកូនមាន់ក្រោយពេលមេវាក្រាប។

## តើអ័រគីដេជាផ្កាខ្មែរឬផ្កាបរទេស ?

«អ័រគីដេ» ជាឈ្មោះផ្កាម្យ៉ាង ជាប្រភេទផ្កាព្រៃ មានដុះក្នុងព្រៃតាមប្រទេសផ្សេងៗជាច្រើន មិនមែនតែនៅប្រទេសកម្ពុជាទេ។ ឈ្មោះអ័រគីដេជាឈ្មោះដែលខ្មែរយើងហៅតាមភាសាបរទេស, ឈ្មោះជាភាសាខ្មែរ គឺ «កេសរកូល»។

ឯកសារនេះរៀបរៀង និងផលិតដោយ ភូ ចរិយា
ដែលអាចឲ្យ download ដោយមិនគិតថ្លៃ
នៅលើគេហទំព័រ https://chantchhaya.com/



**ការពិតរបស់ កូនក្មេង**

នំបញ្ចុកមានសម្លខ្មែរ, សម្លណាំយ៉ា និងសម្លការី។ ខ្ញុំចូលចិត្តញ៉ាំនំបញ្ចុកសម្លខ្មែរ តែខ្ញុំមិនចូលចិត្តដាក់បន្លែទេ ព្រោះបន្លែនំបញ្ចុកជាបន្លែឆៅ, ញ៉ាំហើយ ខ្ញុំឈឺពោះ។

# រ៉ល់ៗ តែសប្បាយ

### ពេលរៀន តើចូលចិត្តម៉ោងណាជាងគេ?

ម៉ោងដែលខ្ញុំចូលចិត្តជាងគេពេលរៀន គឺម៉ោងចេញលេង។

### តើគ្រូហាមមិនឲ្យធ្វើអ្វីពេលកំពុងរៀន?

ពេលកំពុងរៀន អ្នកគ្រូហាមមិនឲ្យញ៉ាំនំ, ប៉ុន្តែពេលនៅក្នុងម៉ោងរៀន អ្នកគ្រូដាក់លំហាត់ឲ្យពួកយើងធ្វើ ហើយគាត់អង្គុយនៅតុ ញ៉ាំបាយព្រឹក រួចគាត់និយាយថា បើគាត់មិនញ៉ាំ, គាត់នឹងគ្មានកម្លាំងបង្រៀនពួកយើងទេ។

### ពេលកំពុងរៀនក្នុងថ្នាក់ តើឆ្ងល់អ្វីជាងគេ?

ពេលកំពុងរៀន ខ្ញុំឆ្ងល់ថា ហេតុអ្វីបានជាអ្នកគ្រូចូលចិត្តស្រែកដាក់ខ្ញុំ និងពួកម៉ាក? ប៉ុន្តែពេលពួកយើងស្រែកដាក់គ្នា គាត់ស្តីឲ្យ ហើយប្រដៅថា ការស្រែកមិនល្អទេ។

### តើចូលចិត្តគូររូបអ្វី? ហេតុអ្វី?

ខ្ញុំចូលចិត្តគូររូបផ្ទះ ព្រោះខ្ញុំចង់មានផ្ទះដែលជារបស់ខ្លួនឯង ដែលខ្ញុំអាចនៅក្នុងនោះ ហើយធ្វើអ្វីក៏បានតាមចិត្តខ្ញុំចង់ ដោយគ្មានអ្នកណាមកប្រាប់ថាត្រូវធ្វើបែបនេះឬបែបនោះ។

### តើពេលណាដែលសប្បាយចិត្តបំផុត?

ពេលដែលខ្ញុំសប្បាយចិត្តបំផុត គឺពេលដែលខ្ញុំរកលុយបានដោយសារយកនំដែលអ្នកផ្ទះឲ្យ ទៅលក់ឲ្យពួកម៉ាក ហើយយកលុយហ្នឹងទៅទិញទឹកត្រជាក់។

